Reading Book

ពិភពរឿងនិទាន

The World of Stories

# ត្រចៀក មាត់ និង ដៃ

# Ear, Mouth and Hands



M.62

ស្រឡាញ់ជាតិ កុំសេពគ្រឿងញៀន

## គោលបំណង

រឿង "**ត្រចៀក មាត់ និង ដៃ**" មានបំណងអប់រំដល់ប្អូនកុមារឱ្យយល់ដឹងពីការថែរក្សាត្រចៀកកុំឱ្យទឹកចូល មិនត្រូវយកឈើត្បារត្រចៀក ឬនៅក្បែរសម្លេងដែលឮខ្លាំងពេកទេ ទាំងនេះបណ្ដាលឱ្យគ្រោះថ្នាក់ដល់ត្រចៀក។ រឿងនេះដែរ ចង់អប់រំប្អូនៗកុមារឱ្យចេះលាងសំអាតដៃមុនពេលកាន់ចំណីបរិភោគ និងសម្អាតធ្មេញបន្ទាប់ពីទទួលទានអាហាររួច។

## Moral

The Ears, Mouth, and Hands is aimed at educating the children on how to keep their ears safe by not letting fluids penetrating the ears, cleaning them with any stick or exposing them to strong noise because it may impair the hearing. The story also teaches the children to wash their hands before they hold food and clean their teeth after meal.



ថ្ងៃមួយ **ត្រចៀក** ស្រែកឆោឡោថា " នរណាធ្វើអីហ្នឹង ? ដូចជាមានអ្នកណាចូលមក ?" ។ ប៉ុន្តែគ្មានសម្លេងឆ្លើយតបសោះ។ **ត្រចៀក** ស្រែកខ្លាំងៗម្តងទៀតថា "នរណាមករកអីហ្នឹង ?" ។

One day, the ears cried out angrily, 'Who's doing in there? It looks like someone is getting in here?' Still, no one answered. The ears roared again, 'Who the hell is that?'



**ដៃ** នៅក្បែរនោះឆ្លើយឡើងថា " ខ្ញុំឃើញសត្វស្រមោច មួយចូលទៅខាងក្នុង " ។ **ត្រចៀក** ប្រាប់ **ដៃ** ថា " ខ្ញុំឃើញវាហើយ តែខ្ញុំគ្មានលទ្ធភាពរាំងវាបានទេ " ។ **ដៃ** តប "បង **ត្រចៀក** នៅឱ្យស្ងៀម ចាំខ្ញុំចាក់ទឹកចូលដើម្បីឱ្យស្រមោចចេញមកក្រៅ " ។ **ត្រចៀក** ឃាត់ " កុំ ៗ ! កុំចាក់ទឹកចូលឱ្យសោះ ព្រោះអាចបណ្តាលឱ្យខ្ញុំកើតជម្ងឺដិបៅអំបែក" ។

The nearby hands said, 'I saw an ant moving in there.' The ears replied, 'I saw it but that I couldn't stop it.' The hands advised, 'Please stay put so that I will be able to pour the water in there to get rid of the ant'. The ears warned, 'Stop! Stop! Please don't do that because it will make me suffer from otitis.'



**ដៃ**តប " បើអ៊ីចឹង ចាំខ្ញុំយកឈើរុកឱ្យវាចេញមក " ។ **ត្រចៀក** ប្រកែកថា " ទេ ! ទេ ! កុំធ្វើដូច្នេះ វាបណ្ដាលឱ្យខ្ញុំធ្លុះបានណា៎ ! បើអ្នកចង់ជួយខ្ញុំ សូមទៅតាមគ្រូពេទ្យមកឱ្យខ្ញុំវិញ" ។



The hands said, 'So, I will use the stick to poke it out.' The ears denied, 'Stop! Stop! Don't do that because it can make my inner part pierced. Well, please call the doctor, and ask him to pull the ant out of me.'

**ផែ**តប " បាន ! ខ្ញុំទៅតាមគ្រូពេទ្យក៏បាន " ។ ក្រោយមកគ្រូពេទ្យបានយកកូនពិលឆ្លុះក្នុងត្រចៀក ឃើញស្រមោចនោះរាងធំ គ្រូពេទ្យក៏គាបសត្វស្រមោចចេញ



ដោយសុវត្ថិភាព តែបើស្រមោចនោះតូចវិញ គ្រូពេទ្យត្រូវប្រើវិធីម្យ៉ាងទៀត គឺយកសំឡីជ្រលក់នឹងទឹកថ្នាំហើយផ្តិតយកស្រមោចនោះចេញមកក្រៅ។ **ត្រចៀក**និយាយទៅកាន់ **ដៃ** ថា " ខ្ញុំអរគុណបងណាស់ កុំតែបានបងជួយខ្ញុំទាន់ មិនដឹងជាខ្ញុំត្រូវដោះស្រាយដោយវិធីណាទេ " ។

The hands replied, 'Ok, I will invite the doctor over here.' Then the doctor used a small torch with which he found a big ant before it was pulled out safely with pincers. If the ant were smaller, the doctor would have applied another method in which the swabs are got soaked with medicinal liquid to take the ant out. The ears said to the hands, 'I really thank you for your timely help. Were it without your assistance, I would have not known what to do with it.'



មិនយូរប៉ុន្មាន **មាត់** ក៏ស្រែក " ចំណីនេះកខ្វក់ណាស់ ? " **ដៃ** នៅវេរាខាងមុខឆ្លើយថា " ប្រហែលមកពីបង **ត្រចៀក** ទេដឹងហ្អាស់បង ! " ។

Not long after which, the mouth yelled, 'This food is not clean!' The hands loitering in front of the mouth said, 'It's probably the ears that made the food unclean!'

**មាត់** ប្រាប់ **ដៃ** ថា " ខ្ញុំ និង **ត្រចៀក** គឺជាមិត្តល្អនឹងគ្នា គាត់មិនដែលបង្កបញ្ហាជាមួយនឹងខ្ញុំម្តងណាទេ " ។ **មាត់** សួរទៅ **ដៃ** ថា " ខ្ញុំឃើញស្រមោល **ដៃ** ឯងជាអ្នកធ្វើមែនទេ ? " ។ **ដៃ** តប " សុំទោសខ្ញុំធ្វើមែន ។



តាមពិតចំណីនេះល្អណាស់ ដោយសារខ្ញុំប្រញាប់ពេក ទើបខ្ញុំពុំបានសម្អាតខ្លួន ក៏ចាប់ចំណីនេះមកជូនបងទៅ" ។ **មាត់** តប " ខ្ញុំឈប់ហូបហើយ សូមឯងយកទៅវិញចុះ តែលើកក្រោយ ត្រូវសម្អាតខ្លួនឱ្យមានអនាម័យសិន មុននឹងមកបំរើអ្នកដទៃ " ។



The mouth said, 'The ears and I are good friends, and they've brought me no trouble at all.' The mouth said to the hands, 'I saw your shadow. You must have done it, didn't you?' 'I'm sorry. I did it. In fact, the food was completely clean and became that filthy as I was in such a rush that I forgot to wash myself before serving you the food,' the hands replied, The mouth said, 'I will eat no more from now. Please take it away, but you have to remember to wash yourself the next time you serve others food.'



**ដៃ** ប្ដេជ្ញាចិត្តថា " ដាច់ខាតខ្ញុំត្រូវសម្អាតខ្លួន ជាពិសេសពេលចេញពីបង្គន់ និងមុនពេលបំរើអាហារ ដល់បងមាត់ បើមិនដូច្នេះទេ យើងនឹងអាចមាន ជម្ងឺបាន"។



The hands earnestly said, 'I would always wash myself first, especially after leaving the toilet and before serving food for the mouth, or we will be infected.'



ក្រោយពី **មាត់** និង **ដៃ** សំរុះសំរួលគ្នាហើយ **ត្រចៀក** ស្រែកឡើងថា " សម្លេងអីក៏ខ្លាំងៗម្ល៉េះ ? " **ដៃ** ឯងជាអ្នកធ្វើមែនទេ ?" ។ **ដៃ** តប "ខ្ញុំធ្វើមែន តែខ្ញុំមិនដែលបង្កសម្លេងខ្លាំងៗនោះទេ ប៉ុន្តែសម្លេងនេះខ្ញុំស្គាល់ច្បាស់ណាស់" ។ **ត្រចៀក** សួរ **ដៃ** ថា "អីចឹងសម្លេងនរណា? ។ **ដៃ** ថា "សម្លេងនេះជាសម្លេងរបស់បង **មាត់** " ។

Once the mouth and the hands agreed to it, the ears cried out, 'What's such a loud noise! The hands made it, didn't you?' 'Of course not, the hands replied, I've never made such a loud noise, but I know who did it very clearly'. The ears asked, 'So, who made the noise then?' The hands answered, 'The mouth is.'



**ត្រចៀក** ប្រាប់ទៅ **មាត់** " កុំស្រែកខ្លាំងៗជិតខ្ញុំពេក អាចបណ្ដាលឱ្យខ្ញុំថ្លង់បានណា ! " ។ **ដៃ** បានស្ទុះទៅខ្ទប់ **មាត់** ហើយ **មាត់** និយាយខ្សិបៗថា " អរគុណ**ដៃ**ហើយ" ។



The ears advised the mouth, 'Please do not make so much noise close to me as it could impair my hearing.' The hands immediately covered the mouth, and the mouth whispered, 'Thank you!'



ចាប់តាំងពីពេលនោះមក **ត្រចៀក មាត់** និង **ដៃ** ក៏ជាមិត្តល្អនឹងគ្នាតទៅ។ **ចប់**

The ears, the mouth and the hands became good friends ever since. The End!

## គិតល្អ និយាយល្អ ធ្វើតែអំពើល្អ នឹងបានផលល្អ

'Thinking positively, speaking well and doing good deeds will bring about good results.'

## សំណួរ

១-ហេតុអ្វីបានជាត្រចៀកមិនឱ្យដៃយកទឹកចាក់ចូលក្នុងត្រចៀក? ហើយក៏មិនឱ្យយកឈើឆ្កឹះត្រចៀក?

២-តើនរណាជាអ្នកយកស្រមោចចេញពីត្រចៀក?

៣-តើនរណាយកចំណីកខ្វក់ដាក់ក្នុងមាត់?

៤-នរណាបង្កសម្លេងនៅក្បែរត្រចៀក?

៥-ដើម្បីឱ្យត្រចៀក មាត់ ដៃ បានល្អតើប្អូនៗត្រូវធ្វើអ្វីខ្លះ?

## Questions

1. Why didn't the ears allow the hands to pour the water and use the stick to poke the ant out?
2. By whom was the ant removed?
3. By whom was the mouth served unclean food?
4. Who made noise near the ears?
5. What should be done to keep your ears, mouth and hands healthy?